សង្កាត់ ៣ មកជា ឃុំ ព្រះបាទ

សង្កាត់សាមគ្គី មកជា ឃុំ សាមគ្គី

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ១៤ អនក្រ
## ស្តីពីការប្តូរឈ្មោះ ទីរួមខេត្ត សង្កាត់ ក្នុងខេត្តកំពត

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្ត កំពត មកជាស្រុក កំពង់បាយ ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិ កំពង់បាយខាងជើង ឃុំ កំពង់បាយ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះ សង្កាត់ចំនួនប្រាំ ចំណុះទីរួមខេត្ត មកជាឃុំចំនួនប្រាំ ចំណុះស្រុកកំពង់បាយ គឺ :

www.pheakdeylaw.com

សង្កាត់ ១ មកជា ឃុំ កំពង់កណ្តាល

សង្កាត់ ២ មកជា ឃុំ ក្រាំងអំពិល

សង្កាត់ ៣ មកជា ឃុំ កំពង់បាយ

សង្កាត់ ៤ មកជា ឃុំ អណ្តូងខ្មែរ

សង្កាត់ ៥ មកជា ឃុំ ត្រើយកោះ

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ១៥ អនក្រ
## ស្តីពីការប្តូរឈ្មោះ ពីរូបខេត្ត សង្កាត់
## ក្នុងខេត្ត ព្រៃវែង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

www.pheakdeylaw.com